LONG BEACH
UNIFIED SCHOOL DISTRICT

# បច្ចុប្បន្នភាពនៃគំរោង LCAP រយៈពេលពាក់កណ្តាលឆ្នាំ

DCAC / DELAC
កុម្ភៈ / មីនា 2022

# ប្រវត្តិទូទៅ

ផ្នែក 124(e) នៃច្បាប់សភា(Assembly Bill) លេខ 130 តំរូវអោយ LEAs បង្ហាញពីព័ត៌មានថ្មីៗអំពីបច្ចុប្បន្នភាពប្រចាំឆ្នាំរបស់គំរោង **LCAP 2021–22** និង **ថវិការទូទៅសំរាប់មាតាបិតា** នៅឬមុនថ្ងៃ **ទី28 ខែកុម្ភៈ ឆ្នាំ 2022** តាមកាលវិភាគប្រជុំជាប្រចាំរបស់គណៈអភិបាលគ្រប់គ្រង។

**ផលប៉ះពាល់នៃ ថវិការទូទៅសំរាប់មាតាបិតា**

មូលនិធិបន្ថែម ដែលត្រូវរាប់បញ្ចូលក្រោយពេលគំរោង LCAP ត្រូវបានអនុម័ត

**អត្ថបទបង្រួបបន្ថែមលើ បច្ចុប្បន្នភាពប្រចាំឆ្នាំ**

ចំណុចទៀងទាត់ប្រាំ - គំរូទំរង់ CDE Template

**លទ្ធផលនិងទិន្នន័យចំណាយ ពាក់កណ្តាលឆ្នាំនៃ គំរោង LCAP 2021-22**

ការចំណាយដែលមានក្នុងពេលបច្ចុប្បន្ន និងគោលដៅទិន្នន័យ

# ការចូលរួម នៃដៃគូអប់រំ

- LBUSD ទទួលបានថវិការសរុបចំនួន **$11.2M** ដុល្លា តាមរយៈច្បាប់ថវិការ (Budget Act) ឆ្នាំ 2021 ដែលត្រូវបានបញ្ជាក់ដោយរដ្ឋ ក្រោយពេលដែលគំរោង LCAP ត្រូវបានអនុម័ត។
- ប្រើប្រាស់ដំណើរការនៃការចូលរួមរៀបចំថវិការ ដែលកំពុងតែដំណើរការទៅមុខ
- នៅខែតុលា ឆ្នាំ 2021, LBUSD បានដាក់ចេញអោយប្រើនូវប្រព័ន្ធ **ThoughtExchange©** ថ្មីមួយ ដែលនឹងស្វែងរកការឆ្លើយតបនានា អំពីថាតើត្រូវធ្វើយ៉ាងណាដើម្បីឧបត្ថម្ភគាំទ្រអោយបានល្អបំផុតនោះ  ចំពោះតំរូវការផ្សេងៗរបស់សិស្ស នៅពេលបច្ចុប្បន្ននិងក្នុងពេលអនាគតកាល។
  - រៀបចំណាយមូលនិធី LCFF, ច្បាប់ Title I មូលនិធិសង្គ្រោះនានារបស់រដ្ឋ និងរដ្ឋាភិបាលសហព័ន្ធ ដែលរួមបញ្ចូលមូលនិធិ ESSER III ថ្មីៗនេះ
  - ការចូលរួម មានរាប់បញ្ចូលអ្នកចូលរួមចំនួន **453** នាក់ ទទួលបានគំនិតផ្សេងៗចំនួន **576** និងអ្នកចូលរួមធ្វើការវាយតម្លៃចំនួន **11,549**
- ប្រធានបទ/គោលគំនិតស្របនានាបានផុសចេញនៅក្នុង **ការឧបត្ថម្ភគាំទ្រការសិក្សា** ធ្វើអោយគាំង និងត្រូវពង្រឹងឡើងវិញនូវជំនឿដែលថា អន្តរាគមន៍បន្ថែមគឺត្រូវការជាចាំបាច់ សំរាប់សាលារៀនដែលមានតំរូវការខ្ពស់បំផុត៖
  - **អន្តរាគមន៍ការសិក្សា**
  - **អន្តរាគមន៍អក្ខរកម្ម**

# ប្រើបណ្ដុំមូលនិធិបន្ថែម

ដោយមានបណ្ដុំមូលនិធិបន្ថែមមកលើប្រាក់សំរាប់ផ្ដល់អោយ និងប្រើការឆ្លើយតបនានាដែលទទួលបានពីការចូលរួមនៃសហគមន៍ ក៏ LBUSD បានចាប់ផ្ដើមបង្រៀនបុគ្គលិកនៅតាមសាលារៀនទាំងឡាយណា ដែលមានការចុះឈ្មោះចូលរៀនយ៉ាងហោចណាស់ 55% នៃសិស្សដែលមានការលំបាកក្នុងការសិក្សា។

LBUSD បានជួលបុគ្គលិកចំនួន **91នាក់ ដែលទទួលតួនាទីបំរើការងារពេញម៉ោង** (FTE)

**គ្រូបង្រៀនអក្ខរកម្ម**

# ដៃគូចូលរួមក្នុងការអប់រំ
# សំរាប់ថវិការដែលទទួលបានចំនួនមួយដងពីមូលនិធិសហព័ន្ធ

- ដំណើរការចូលរួមរៀបចំថវិការ
- ចាប់ផ្តើមជាថ្មីនៅខែកុម្ភៈ ឆ្នាំ 2022៖ Thought Exchange© (lbschools.net/LCAP)

**ខណៈដែលយើងបន្តអនុវត្តនូវកម្មវិធីនិងការគាំទ្រដែលមានចែងក្នុងគំរោង LCAP គំរោងការពន្លឿនការសិក្សានិងជំនួយទូទៅ (LASP) និងគំរោងសង្គ្រោះបន្ទាន់នៃសាលាបឋមសិក្សានិងវិទ្យាល័យ III (ESSER III) តើមានការឧបត្ថម្ភគាំទ្របន្ថែមអ្វីខ្លះដែលត្រូវតែធ្វើការពិចារណាទៅលើ?**

សូមដាក់ទៅក្នុងការពិចារណា ដែលមូលនិធិជាក់លាក់មួយចំនួន ដែលរួមបញ្ចូលច្បាប់ Title I និងបណ្តុំមូលនិធិ បន្ថែម LCFF តំរូវតាមក្រុមគាំទ្រគោលដៅ សំរាប់សិស្សនិងសាលារៀនដែលមានតំរូវការខ្ពស់បំផុត។

- ការសន្ទនានៅក្នុងកិច្ចប្រជុំក្រុមមាតាបិតានៅមណ្ឌលដែលនឹងមានរៀបចំឡើង
- គំនិតចែករំលែក នឹងប្រើជាព័ត៌មានសំរាប់ការបង្កើតនូវគំរោង LCAP **ឆ្នាំសិក្សា 2022-23**


ការចូលរួមនិងការធ្វើថវិការ
ការចូលរួមធ្វើថវិការ
ឆ្នាំសិក្សា 2020-2021
thoughtexchange
និង
កិច្ចប្រជុំមាតាបិតា
ការចូលរួមនិងការធ្វើថវិការ
ការចូលរួមធ្វើថវិការ
ឆ្នាំសិក្សា 2021-2022
thoughtexchange
និង
កិច្ចប្រជុំមាតាបិតា
សំណួរណែនាំមួយចំនួន
តើការអនុវត្តន៍អ្វីខ្លះដែលមានប្រសិទ្ធិភាពជាងគេ ក្នុងការដោះស្រាយលើ៖
• ការគាំទ្រលើការសិក្សា?
• ការសិក្សាពីអារម្មណ៍ផ្លូវសង្គម?
• ការចូលរួមនៃនិងការលើកទឹកចិត្តដល់សិស្ស?
ប្រធានបទសមញ្ញៗ- កម្មវិធី និង សេវាកម្មនានា
• បច្ចេកវិទ្យា ការអភិវឌ្ឍវិជ្ជាជីវៈ អន្តរាគមន៍ ការបង្ហាត់
• ការផ្តល់ប្រឹក្សាយោបល់ ការផ្សារភ្ជាប់ទំនាក់ទំនង សុខភាពផ្លូវចិត្ត
• ទំហំថ្នាក់រៀន ការផ្សារភ្ជាប់ទំនាក់ទំនង ការរៀនសូត្រដោយមានការចូលរួម
ESSER III
ខែតុលា 2021
ELO
ខែឧសភា 2021
LASP
រដូវក្តៅ/រដូវស្លឹកឈើជ្រុះ
ឆ្នាំសិក្សា 2021
LCAP
ខែមិថុនា 2021
LASP
2.0
LCAP
ខែមិថុនា 2022
ដំណើរការកំពុងតែវិវត្តទៅមុខ

# ការអនុវត្តនូវ គំរោចចំណាយលើច្បាប់ ESSER III

ESSER III គ្រោងអំពាវនាវអោយមានការចំណាយ ដែលនឹងចាប់ផ្តើមនៅក្នុងឆ្នាំសារពើពន្ធ 2022-23។

## ថវិការ

- ការអនុវត្តនូវយុទ្ធសាស្រ្តនានា សំរាប់សុវត្ថភាពនិងការបន្តចូលរៀនដោយផ្ទាល់៖ $85,368,965
- ដោះស្រាយការសិក្សាដែលទទួលផលប៉ះពាល់ពីពេលវេលាបង្រៀនដែលបានបាត់បង់៖ $82,810,000
- ការអនុវត្តនូវសកម្មភាពបន្ថែមនានា៖ $43,870,000

# ការប្រើប្រាស់ ធនធានសារពើពន្ធផ្សេងៗ ដែលស្របជាមួយនឹងគំរោង LCAP

## LCAP

- ចំណុចកំពូលនៃដំណើរការចូលរួមរៀបចំថវិការរបស់ LBUSD
- មូលដ្ឋានគ្រឹះនៃមូលនិធិនៃកម្មវិធីមូលដ្ឋានរបស់មណ្ឌលសាលា។
- បណ្តុំការផ្តល់ថវិការបន្ថែម សំរាប់កម្មវិធីនិងសេវាកម្មនានា ដែលមានបំណងតំរូវទៅតាមសេចក្តីត្រូវការរបស់សិស្សដែលមានការលំបាកក្នុងការសិក្សា (សេវាអប់រំបន្ថែម (SES) ដែលមានកំរិតទាប សិស្សដែលកំពុងរៀនភាសាអង់គ្លេស (EL) និងសិស្ស/យុវជនចិញ្ចឹម (Foster))

**ការសំរបសំរួលនូវធនធនធាននានា តាមរយៈដំណើរការនៃការចូលរួមរៀបចំថវិការ គឺការពារកុំអោយមានសេវាកម្មតែឯកឯងណាមួយដែលអាចនឹងមិនមាននិរន្តរភាព។**

## LASP

- ច្របាច់បញ្ចូលគ្នានូវធនធានផ្សេងៗជាច្រើន
- *សរសេរទ្រទ្រង់នៃតំរូវការ* □ *កម្មវិធីនិងសេវាកម្មនានា* □ *កំណត់សំគាល់ធនធាន*

# ផលប៉ះពាល់នៃ ថវិការជាទូទៅសំរាប់មាតាបិតា

នៅពេលដែល LBUSD ចេញគំរោង LCAP និងគំរោងថវិការរបស់យើង នៅខែមិថុនា ឆ្នាំ 2021 គឺច្បាប់ថវិការរដ្ឋមិនទាន់ធ្វើចប់នៅឡើយទេ។ ច្បាប់ថវិការរដ្ឋដែលបានអនុម័ត មានបញ្ចូលមូលនិធិបន្ថែម ដែលមិនត្រូវបានគ្រោងទុកដោយមណ្ឌលនោះឡើយ។ ផលប៉ះពាល់ទៅលើថវិការជាទូទៅសំរាប់មាតាបិតា (BOP) របស់យើងដែលត្រូវបានអនុម័តមានដូចតទៅ៖

| វត្ថុ | ដូចអនុម័តក្នុង BOP | ទឹកប្រាក់មានក្នុងច្បាប់ថវិការនីមួយៗ | របាយការណ៍វិវត្តលើកទី១ | ការគ្រោងទុលដោយផ្អែកលើ CALPADS |
|---|---|---|---|---|
| **កាលបរិច្ឆេទ** | **មិថុនា 2021** | **សីហា 2021** | **តុលា 2021** | **មីនា 2022** (ការគ្រោងទុក) |
| សរុប មូលនិធិ LCFF | $752.4M | $763.6M | $759.6M | $756.1M |
| ថវិការបន្ថែម និង បណ្ដុំប្រាក់សំរាប់ផ្ដល់អោយ របស់មូលនិធី LCFF | $120.6M | $131.8M | $127.8M | $124.3M |

# ការចំណាយរបស់ LCAP

**គោលដៅទី 1**
សេវាកម្មមូលដ្ឋាន

**គោលដៅទី 2**
សាលាមានការឧបត្ថមគាំទ្រ

**គោលដៅទី 3**
ការវិវត្តនៃសិក្សា

**គោលដៅទី 4**
ការត្រៀមជាស្រេច សំរាប់មហាវិទ្យាល័យ និងអាជីព

**គោលដៅទី 5**
ការចូលរួមយ៉ាងសកម្ម






# ការចំណាយរបស់ LCAP

**គោលដៅទី 1**
សេវាកម្មមូលដ្ឋាន

**គោលដៅទី 2**
សាលាមានការឧបត្ថម្ភគាំទ្រ

**គោលដៅទី 3**
ការវិវត្តនៃសិក្សា

**គោលដៅទី 4**
ការត្រៀមជាស្រេច សំរាប់ មហាវិទ្យាល័យ និងអាជីព

**គោលដៅទី 5**
ការចូលរួមយ៉ាងសកម្ម



# ការចំណាយរបស់ LCAP៖ ការពង្រីកនិងវិស័យផ្ដោតគោលដៅថ្មី

- **មជ្ឈមណ្ឌលសុខុមាលភាពវិទ្យាល័យ** (គោលដៅទី 5)
  បង្កើតមជ្ឈមណ្ឌលគាំទ្រសេវាកម្ម SEL ថ្មី នៅតាមវិទ្យាល័យទាំងអស់
- **ការពង្រីកកម្មវិធីសិស្សដែលគ្មានលំនៅដ្ឋាននិងយុវជនចិញ្ចឹម** (គោលដៅទី 5)
  អ្នកធ្វើការខាងសង្គមកិច្ចថ្មីៗ
- **ការពង្រីកកម្មវិធីអក្ខរកម្ម**(គោលដៅទី 3)
  ការអភិវឌ្ឍវិជ្ជាជីវៈ
  ការឧបត្ថម្ភសម្ភារៈបន្ថែម
- **សម្ភារៈសិក្សាដែលឆ្លើយទៅនឹងវប្បធម៌** (គោលដៅទី 3)
- **ការឧបត្ថមដល់សិស្សដែលកំពុងសិក្សាភាសាអង់គ្លេស** (គោលដៅទី 3)
  តំណែង/មុខងារអ្នកបកប្រែថ្មីៗ

បច្ចុប្បន្នភាពរយៈពេលពាក់កណ្តាលឆ្នាំ

# ឧបករណ៍វាស់ស្ទង់ របស់ LCAP

មកដល់ត្រឹមចំណុចនេះនៅក្នុងឆ្នាំសិក្សា លទ្ធផលនៃឧបករណ៍វាស់ស្ទង់មួយចំនួនត្រូវបានដឹងហើយ លទ្ធផលខ្លះកំពុងតែដំណើរការ និងលទ្ធផលខ្លះទៀតមិនត្រូវបានដឹងនៅឡើយទេ

| | |
|---|---|
| **គោលដៅទី 1:** សិស្សនឹងទទួលបានសេវាកម្មមូលដ្ឋាននានាដែលជាគ្រឹះឈានទៅរកការសំរេចជោគជ័យក្នុងការសិក្សា រួមបញ្ចូលគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិល្អ សម្ភារៈបង្រៀនដែលស្របនឹងបទដ្ឋាន និងសេវាដ្ឋានសាលារៀនដែលមានការរក្សាថែទាំបានល្អ | |
| អត្រានៃការអនុវត្តតាមតំរូវការនៃ **សម្ភារៈបង្រៀន** (ដំណោះស្រាយអោយមានសៀវភៅគ្រប់គ្រាន់) | LBUSD បានផ្តល់អោយសិស្សនីមួយៗនូវ **សៀវភៅនិងសម្ភារៈណែនាំគ្រប់គ្រាន់** ដែលស្របទៅតាមបទដ្ឋាននានានៃមាតិកាការសិក្សា។ |
| ភាគរយនៃសាលារៀនដែលស្ថិតក្នុងស្ថានភាព "ល្អ" ឬ **ការជួសជុលជា "គំរូ"** (ឧបករណ៍សំរាប់ធ្វើសវនកម្មលើសេវាដ្ឋាន) | **សាលាចំនួន 82 ក្នុងចំណោមសាលា 83** ទទួលបានអត្រា "ល្អ" ឬ ការជួសជុលជា "គំរូ" យោងតាមរបាយការណ៍សវនកម្មនៃសេវាដ្ឋានឆ្នាំ 2021 - **99%** |
| **គោលដៅទី 2:** សាលារៀនជាកន្លែងដែលមានសុវត្ថភាព កន្លែដែលចង់ទៅ កន្លែងចង់ចូលរួម និងកន្លែមានការគាំទ្រ សំរាប់សិស្ស មាតាបិតា និងបុគ្គលិក | |
| ចំនួនជាមធ្យមនៃអ្នកចូលទស្សនាសិក្ខាសាលាមាតាបិតានីមួយៗ តាមរយៈ **សិក្ខាសាលាតាមអ៊ីនធឺណេត** ជាភាសាអង់គ្លេស អេស្ប៉ាញ និងខ្មែរ។ | **1,769** ជាចំនួនអ្នកចូលទស្សនាព្រឹត្តិការណ៍ប្រជុំមាតាបិតា (Parent U) ចាប់ពីថ្ងៃទី28 ខែសីហា ឆ្នាំ2021 - ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ2022 (អ្នកចូលទស្សនាសរុបមានចំនួន **21,229**) |
| **គោលដៅទី 3:** សិស្សមានការវិវត្តការសិក្សាចំរើនទៅមុខ ដោយផ្អែកទៅលើបទដ្ឋានស្នូលរបស់រដ្ឋ ដើម្បីអោយពួកគេអាចត្រៀមជាស្រេចសំរាប់ទាំងចូលសិក្សានៅមហាវិទ្យាល័យ និងចាប់យកអាជីព នៅពេលបញ្ចប់ការសិក្សានៅវិទ្យាល័យ។ *(ទិន្នន័យទាំងអស់នៃឧបករណ៍វាស់ស្ទង់កំពុងតែមានដំណើរការវិវត្ត)* | |

# ឧបករណ៍វាស់ស្ទង់ របស់ LCAP

| គោលដៅទី 4: សិស្សបង្ហាញពីការត្រៀមជាស្រេចក្នុងការចូលសិក្សានៅមហាវិទ្យាល័យ និងចាប់យកអាជីព។ | |
|---|---|
| ភាគរយនៃសិស្សដែលបញ្ចប់ការសិក្សានៅវិទ្យាល័យដែលចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យ ដែលមានរយៈពេលពីរឆ្នាំ ឬបួនឆ្នាំ (National Student Clearinghouse) | 66.6% នៃសិស្សដែលបញ្ចប់ការសិក្សានៅវិទ្យាល័យ ដែលបានចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យ ដែលមានរយៈពេលពីរឆ្នាំ ឬបួនឆ្នាំ (ថ្នាក់នៃឆ្នាំសិក្សា 2021) |
| ភាគរយនៃសិស្សថ្នាក់ទី 11 និងទី12 ដែលចុះឈ្មោះចូលរៀនយ៉ាងតិចចំនួនមួយវគ្គ នៃវគ្គសិក្សា **Advanced Placement course.** (College Board) | 48.7% នៃសិស្សថ្នាក់ទី 11 និងទី 12 ដែលកំពុងត្រូវចុះឈ្មោះចូលរៀនយ៉ាងតិចចំនួនមួយវគ្គ នៃវគ្គសិក្សា AP។ |
| **គោលដៅទី 5: សិស្សនឹងចូលរួមក្នុងការសិក្សារបស់គេយ៉ាងសកម្ម ដើម្បីបំពេញតាមបទដ្ឋានស្នូលរបស់រដ្ឋ និងត្រៀមជាស្រេចសំរាប់ចូលសិក្សានៅមហាវិទ្យាល័យ និងចាប់យកអាជីព។** | |
| អត្រាវត្តមាន (CALPADS) | ទិន្នន័យពាក់កណ្តាលឆ្នាំ៖ 90% |
| អត្រាអវត្តមានជាប្រចាំ/រ៉ាំរ៉ៃ (California School Dashboard) | ទិន្នន័យពាក់កណ្តាលឆ្នាំ៖ 25% |
| អត្រាព្យួរសិស្ស (DataQuest) | ទិន្នន័យពាក់កណ្តាលឆ្នាំ:៖1.7% |

# ឧបករណ៍វាស់ស្ទង់របស់ LCAP: នឹងមកដល់ក្នុងពេលឆាប់ៗនេះ!

**កិច្ចការគ្រូបង្រៀន៖** នៅចុងខែ កុម្ភៈ – SARC (គោដៅទី 1)

**ទិន្នន័យនៃការស្ទង់មតិលើកម្មវិធីស្នូល (CORE)** - នឹងត្រូវរៀបចំឡើងនៅខែ មីនា (គោលដៅទី 2)

**ប្រព័ន្ធវាយតម្លៃមានតុល្យភាពនិងឆ្លាតវៃរបស់រដ្ឋកាលីហ្វ័រញ៉ា (CA Smarter Balanced Assessments)** - នឹងត្រូវរៀបចំឡើងនៅរដូវរំហើយ Spring (គោលដៅទី 3 និង 4)

**ទិន្នន័យនៃការចេះភាសាអង់គ្លេសស្ទាត់ជំនាញ (ELPAC)** - នឹងត្រូវរៀបចំឡើងនៅខែ កុម្ភៈ - ឧសភា (គោលដៅទី 3)

**ការត្រៀមជាស្រេចនៅវិទ្យាល័យ** - ពន្ទុ អវត្តមាន ការព្យួរសិស្ស - នៅពេលចុងឆ្នាំ (គោលដៅទី 4)

**ការត្រៀមជាស្រេចសំរាប់ចូលមហាវិទ្យាល័យនិងចាប់យកអាជីព** - វិធានការផ្សេងៗជាច្រើន នៅពេលចុងឆ្នាំ (គោលដៅទី 4)

**អត្រានៃការបោះបង់ការសិក្សា** - នឹងត្រូវគណនា នៅពេលចុងឆ្នាំ (គោលដៅទី 5)

**អត្រានៃការបញ្ចប់ការសិក្សា និងបំពេញបាននូវថ្នាក់តំរូវ A-G** - នឹងត្រូវគណនា នៅពេលចុងឆ្នាំ (គោលដៅទី 5)

**ការប្រឡង AP** - នឹងត្រូវរៀបចំឡើងនៅរដូវរំហើយ Spring (គោលដៅទី 5)

# អំពាវនាវសុំអោយធ្វើសកម្មភាពលើ៖ គំរោង LCAP ឆ្នាំសិក្សា 2022-23

- **ការចូលរួមធ្វើថវិការផ្តោតទៅលើគំនិតជាច្រើន សំរាប់កម្មវិធីនិងសេវាកម្មនានា ដែលបំពេញទៅតាមតំរូវការរបស់សិស្ស។**

- ដើម្បីចាប់ផ្តើម៖ Thought Exchange© - នឹងដាក់ចេញប្រើនៅសប្តាហ៍ក្រោយ៖

**lbschools.net/LCAP**

- សូមតាមដាន ដោយមានការសន្ទនាក្នុងកិច្ចប្រជុំក្រុមមាតាបិតានៅមណ្ឌលដែលនឹងមានរៀបចំឡើងព្រមទាំងសកម្មភាពចូលរួមផ្សេងៗទៀត។

- គំនិតចែករំលែក នឹងប្រើជាព័ត៌មានសំរាប់ការបង្កើតនូវគំរោង LCAP ឆ្នាំសិក្សា 2022-23

# ការបិទកិច្ចប្រជុំ

ផលប៉ះពាល់ដែលបន្តមានដោយសារជំងឺរាតត្បាតខូវីដ-19 រួមបញ្ចូលបញ្ហាព្រួយបារម្ភនៃការរើសបុគ្គលិក ការអនុវត្តន៍ពិធីការខផ្នែកសុខភាពនិងសុវត្ថិភាព និងការដោះស្រាយតំរូវការនានានៃការពន្លឿនការសិក្សា ដោយសារតែផលប៉ះពាល់នៃការរៀនពីចម្ងាយ បង្ហាញនូវបញ្ហាព្រួយបារម្ភជាច្រើនក្នុងរយៈពាក់កណ្តាលឆ្នាំដំបូងនៃឆ្នាំសិក្សានេះ។

**ទោះជាមានបញ្ហាព្រួយបារម្ភច្រើនទាំងនេះក៏ដោយចុះ មណ្ឌលសិក្សាសាលាឡុងប៊ិក ប្តេជ្ញាចិត្តនឹងអនុវត្តនូវគំរោង LCAP ដើម្បីផ្តល់នូវសេវាកម្មចាំបាច់នានាទៅដល់សិស្សរបស់យើងអោយខាងតែបាន។**

យើងទទួលស្គាល់និងថ្លែងអំណរគុណដោយស្មោះស្ម័គ្រចំពោះការខិតខំធ្វើការនិងការប្តេជ្ញាចិត្តរបស់បុគ្គលិករបស់យើង ការឧបត្ថម្ភគាំទ្រពីសំណាក់មាតាបិតា និងការតស៊ូដ៏ស្វិតស្វាញនៃសិស្សរបស់យើង ដើម្បីបន្តឈានទៅទទួលបាននូវឧត្តមភាព។